នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Aug-2012, 09:46
CMS/CFO: Phok Chanthan

ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១២

ភាសាដើម: អង់គ្លេស

សាធារណៈ/Public

~~សម្ងាត់បំផុត/Strictly Confidential~~

របាយការណ៍សង្ខេបរបស់អ្នកជំនាញពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ

ដាក់ឯកសារជូនដោយ៖

វេជ្ជបណ្ឌិត Seena FAZEL

អ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រព្យាបាលជំងឺ និងវេជ្ជបណ្ឌិតពិគ្រោះយោបល់កិត្តិយសផ្នែកវិកលវិទ្យានីតិវេជ្ជសាស្ត្រ សាកលវិទ្យាល័យ Oxford ចក្រភពអង់គ្លេស

សាស្ត្រាចារ្យ **John CAMPBELL**

សាស្ត្រាចារ្យជំនាញព្យាបាលរោគមនុស្សចាស់នៃសាកលវិទ្យាល័យ Otago ប្រទេសណូវែលហ្សេឡង់

វេជ្ជបណ្ឌិត ហួត លីនណា

ជាសាស្ត្រាចារ្យរងផ្នែកវិកលវិទ្យានៃសាកលវិទ្យាល័យអន្តរជាតិ

ប្រធានផ្នែកពិគ្រោះជំងឺផ្លូវចិត្តនៃមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា

សេចក្តីផ្តើម

1. យើង វេជ្ជបណ្ឌិត Fazel, Campbell, និង ហួត លីនណា នឹងជួយដល់អង្គជំនុំជម្រះដោយសេចក្តីស្មោះត្រង់ គោរពគោលការណ៍រក្សាការសម្ងាត់ និងព្យាយាមឲ្យអស់ពីសមត្ថភាពរបស់យើងខ្ញុំ។
2. យើងសូមផ្តល់នូវរបាយការណ៍នេះ ដោយអនុលោមទៅតាមសំណើសុំវាយតម្លៃឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូង[1]។
3. របាយការណ៍នេះជាឯកសារសម្ងាត់បំផុត និង សម្រាប់តែអង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់តែប៉ុណ្ណោះ។ យើងមិនអនុញ្ញាតឲ្យផ្សព្វផ្សាយចំណុចណាមួយនៃរបាយការណ៍នេះជាសាធារណៈ ឬដោយមូលហេតុណាមួយឡើយ ដោយមិនមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធទាំងអស់។
4. របាយការណ៍នេះត្រូវអានរួមគ្នាជាមួយនឹងរបាយការណ៍មុនរបស់យើង ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១១[2]។

ឯកសារពិគ្រោះ

5. E12/67 របាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ ពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២។
6. E12/68 របាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ ពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១២

---

[1] ឯកសារលេខ E138/1/7/13, ERN 00818575 – 00818576, ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២។

[2] ឯកសារលេខ E111/8, ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១១។ សូមកត់សម្គាល់ថាមានកំហុសមួយត្រង់កថាខណ្ឌ២១ នៃរបាយការណ៍នេះ ត្រង់កន្លែងដែលយើងបាននិយាយថា អៀង ធីរិទ្ធ “អាចចាំវត្ថុមួយក្នុងចំណោមវត្ថុទាំងបី ដែលយើងខ្ញុំប្រើក្នុងពេលធ្វើតេស្តទាំងពីរលើក” ដែលវាគួរតែថា អៀង ធីរិទ្ធ “មិនអាចចាំវត្ថុមួយក្នុងចំណោមវត្ថុទាំងបី ដែលយើងខ្ញុំប្រើក្នុងពេលធ្វើតេស្តទាំងពីរលើក”។ ត្រង់នេះត្រូវបានលើកឡើងត្រង់កថាខណ្ឌ ២៤ នៃរបាយការណ៍ដដែលនេះ។

7. E12/68/1 របាយការណ៍វេជ្ជសាស្ត្រប្រចាំ ឆមាស ពីថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១១ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០១២
8. E12/68/1.1 របាយការណ៍វេជ្ជសាស្ត្រប្រចាំ ឆមាស ពីខែតុលា ឆ្នាំ ២០១១ ដល់ខែ មេសា ឆ្នាំ២០១២
9. E12/68/1.2 1 របាយការណ៍វេជ្ជសាស្ត្រប្រចាំ ឆមាស ពីខែតុលា ឆ្នាំ ២០១១ ដល់ខែ មេសា ឆ្នាំ២០១២
10. E12/69 របាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ ពីថ្ងៃទី ០៣ ដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២
11. E12/70 របាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ ពីថ្ងៃទី ១០ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២
12. E12/71 របាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១២
13. E12/72 របាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១២
14. E12/73 របាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ ពីថ្ងៃទី ៣១ ខែឧសភា ដល់ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២
15. E12/74 របាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ ពីថ្ងៃទី ០៧ ដល់ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១២
16. E138/1/7 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ
17. E138/1/7/1 សំណើទៅអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខជំទាស់នឹងការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ (ឯកសារ E138/1/7)
18. E138/1/7/2 អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "បច្ចុប្បន្នភាពពាក់ព័ន្ធនឹងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ទៅអ្នកជំនាញវេជ្ជសាស្ត្រ ស្នើសុំព័ត៌មានថ្មីៗពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ"

19. E138/1/7/3 ការធ្វើបច្ចុប្បន្នភាពបន្ថែម ពាក់ព័ន្ធនឹងសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ទៅអ្នកជំនាញវេជ្ជសាស្ត្រដោយស្នើសុំព័ត៌មានថ្មីៗទាក់ទិននឹងជនជាប់ចោទ អៀង ធីរិទ្ធ
20. E138/1/7/4 របាយការណ៍ទាក់ទងនឹងលោកស្រី អៀង ធីរិទ្ធ ដាក់ជូនតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២
21. E138/1/7/4.1 របាយការណ៍វេជ្ជសាស្ត្រ របស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១
22. E138/1/7/4.2 របាយការណ៍វេជ្ជសាស្ត្រ របស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១១
23. E138/1/7/4.3 របាយការណ៍វេជ្ជសាស្ត្រ របស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១
24. E138/1/7/5 សំណួរពាក់ព័ន្ធនឹងអនុសាសន៍សម្រាប់កម្មវិធីជំរុញផ្នែកបញ្ញាស្មារតី
25. E138/1/7/6 អនុសាសន៍សម្រាប់ការព្យាបាលបន្ថែមទៅលើជនជាប់ចោទ អៀង ធីរិទ្ធ
26. E138/1/7/7 ចម្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងអនុសាសន៍របស់អ្នកជំនាញវេជ្ជសាស្ត្រ
27. E138/1/7/8 អនុស្សរណៈរបស់ការិយាល័យរដ្ឋបាល កម្មវត្ថុ "បញ្ជូនចម្លើយតបពីអនុសាសន៍សម្រាប់ការព្យាបាលបន្ថែមទៅលើជនជាប់ចោទ អៀង ធីរិទ្ធ"
28. E138/1/7/8.1 ចម្លើយតបអំពីអនុសាសន៍សម្រាប់ការព្យាបាលបន្ថែមទៅលើជនជាប់ចោទ អៀង ធីរិទ្ធ
29. E138/1/7/9 ចម្លើយតបរបស់អ្នកជំនាញចំពោះសំណួរពាក់ព័ន្ធនឹងរយៈពេលព្យាបាលដោយឱសថ rivastigmine និងក្របខណ្ឌពេលវេលាសម្រាប់ការវាយតម្លៃឡើងវិញអំពីសម្បទាដើម្បីចូលរួមសវនាការរបស់ជនជាប់ចោទ អៀង ធីរិទ្ធ
30. E138/1/7/10 ការអនុវត្តអនុសាសន៍របស់អ្នកជំនាញស្ដីពីកម្មវិធីលើកកម្ពស់សតិបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ

31. E138/1/7/11 ទាក់ទងនឹងចម្លើយតបរបស់មន្ទីរពេទ្យទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពី "ការអនុវត្តអនុសាសន៍របស់អ្នកជំនាញស្តីពីកម្មវិធីលើកកម្ពស់សតិបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ"
32. E138/1/7/11.1 ឧបសម្ព័ន្ធ១៖ ការឧទ្ទេសនាមមន្ត្រីរាជការពីររូបនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត (KSFH)
33. E138/1/7/11.2 ឧបសម្ព័ន្ធ២៖ លិខិតឧទ្ទេសនាម
34. E138/1/7/12 របាយការណ៍នៃកម្មវិធីបណ្តុះបណ្តាលស្តីពីការលើកម្ពស់សតិបញ្ញាស្មារតីសម្រាប់ អៀង ធីរិទ្ធ
35. E138/1/7/12.1 ឧបសម្ព័ន្ធ១៖ តារាងកម្មវិធីបណ្តុះបណ្តាល
36. E138/1/7/12.2 ឧបសម្ព័ន្ធ២៖ កម្មវិធីប្រចាំថ្ងៃសម្រាប់ អៀង ធីរិទ្ធ
37. E12/58-82 របាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១២ ដល់ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២

ការវាយតម្លៃ

38. យើងបានសម្ភាសន៍លោកស្រី អៀង ធីរិទ្ធ ចំនួនបីលើក គឺនៅថ្ងៃទី ២៧ និងថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២ ដោយមានជំនួយពីអ្នកបកប្រែ គឺ [redacted]។

39. យើងក៏បានសម្ភាសន៍សាស្ត្រាចារ្យ ចក ធីតា ដែលជាវេជ្ជបណ្ឌិតម្នាក់ក្នុងចំណោមវេជ្ជបណ្ឌិតឯកទេសផ្នែកវិកលវិទ្យាទូទៅបម្រើការនៅមន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត ដែលពីមុនមកធ្លាប់បានពិនិត្យលោកស្រី អៀង ធីរិទ្ធ ក្នុងនាមជាវេជ្ជបណ្ឌិតម្នាក់ដែលផ្តល់ការថែទាំវេជ្ជសាស្ត្រដល់លោកស្រី។ យើងពិនិត្យមើលរបាយការណ៍ចំនួនបីអំពីការត្រួតពិនិត្យស្ថានភាពផ្លូវចិត្តរយៈពេលខ្លី ដែលធ្វើឡើងដោយសាស្ត្រាចារ្យ ចក ធីតា ក្នុងឆ្នាំ ២០១១[3] និងមួយទៀតធ្វើឡើងក្នុងឆ្នាំ ២០១២ (ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២)[4]។ លើសពីនេះទៀត យើងបានសម្ភាសន៍វេជ្ជបណ្ឌិត [redacted] ដែលជាវេជ្ជបណ្ឌិតម្នាក់ក្នុងចំណោមវេជ្ជបណ្ឌិតព្យាបាល

[3] E138/1/7/4.3
[4] E12/68/1.1

មួយចំនួនដែលអញ្ជើញមក មន្ទីរឃុំឃាំងជារៀងរាល់សប្តាហ៍។ យើងក៏បាននិយាយតាមទូរស័ព្ទជាមួយនឹងលោក SREEDHARAN Sudev ដែលជាអ្នកជំនាញក្នុងការការព្យាបាលដោយចលនា បម្រើការនៅ OzWorks Therapy Ltd ក្នុងប្រទេសសិង្ហបុរី ដោយអ្នកជំនាញរូបនេះក៏បានផ្តល់ការបណ្តុះបណ្តាល នៅថ្ងៃទី ៣ និងទី ៤ ខែ ឧសភា ឆ្នាំ ២០១២ និងក្រោយមកបានធ្វើការត្រួតពិនិត្យ បុគ្គលិកជាបន្តបន្ទាប់នៅក្នុងការរៀបចំកម្មវិធីជំរុញផ្នែកបញ្ហាស្មារតីសម្រាប់លោកស្រី អៀង ធីរិទ្ធ។ យើងក៏បាននិយាយជាមួយលោក ម៉ៅ សុភារម្យ ប្រធានមន្ទីរឃុំឃាំង ដែលបានស្គាល់លោកស្រី អៀង ធីរិទ្ធ តាំងពីលោកស្រីចាប់ផ្តើមជាប់ឃុំឃាំងក្នុងឆ្នាំ ២០០៧ មកម្ល៉េះ និងអ្នកយាមជាស្ត្រីចំនួនពីរនាក់ [redacted] និ[redacted]។ បន្ទាប់មក យើងបានសម្ភាសន៍ជាមួយ [redacted] ជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលពីរនាក់ដែលលោក SREEDHARAN បានបណ្តុះបណ្តាល ដែលជាអ្នកជំនាញព្យាបាលរោគដោយចលនា និងបានព្យាបាលលោកស្រី អៀង ធីរិទ្ធ តាំងពីដើមខែឧសភា ឆ្នាំ ២០១២ មក។ សាស្ត្រាចារ្យ Campbell ជាផ្នែកមួយនៃការពិនិត្យផ្នែកវេជ្ជសាស្ត្រក៏បាននិយាយជាមួយនឹងលោក អៀង សារី ដែលជាស្វាមីរបស់លោកស្រី នៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២។ បន្ទប់របស់លោក អៀង សារី ស្ថិតនៅទល់មុខបន្ទប់លោកស្រី អៀង ធីរិទ្ធ។

40. សាស្ត្រាចារ្យ ចក ធីតា បានបញ្ជាក់នៅក្នុងរបាយការណ៍របស់លោកស្រី ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ ថា លោកស្រី អៀង ធីរិទ្ធ "ពុំមានការចងចាំភ្លាមៗ [sic]" ហើយថាមានការរាយការណ៍ថា លោកស្រី អៀង ធីរិទ្ធ ទទួលទានដំណេកនៅលើ "គ្រែក្រោមគេ"[3]។ នៅពេលដែលយើងសាកសួរបញ្ជាក់អំពីការដេកនៅលើគ្រែក្រោមគេនោះ សាស្ត្រាចារ្យ ចក ធីតា បាននិយាយថា លោកស្រី អៀង ធីរិទ្ធ ជឿថា មានគេដេកនៅពីលើគាត់នៅក្នុងមុង ប៉ុន្តែ សាស្ត្រាចារ្យ ចក ធីតា គិតថា ប្រហែលជាសត្វពីងពាង ដូច្នេះវាមិនមែនជាការបាត់បង់ស្មារតីឡើយ។ ទាក់ទិននឹងការចងចាំរបស់លោកស្រី សាស្ត្រាចារ្យ ចក ធីតា បានបញ្ជាក់ថា លោកស្រី អៀង ធីរិទ្ធ មិនអាចចងចាំប្រធានបទនៃការសន្ទនា មួយឬពីរនាទីក្រោយពីការសន្ទនាបានចាប់ផ្តើមទេ។ នៅពេលដែលយើងសួរសាស្ត្រាចារ្យ ចក ធីតា អំពីការដឹងអំពីពេលវេលារបស់លោកស្រី អៀង ធីរិទ្ធ (ដែលមាន៥ពិន្ទុនៅតេស្តត្រួតពិនិត្យស្ថានភាពផ្លូវចិត្តរយៈពេលខ្លី) លោកស្រីសាស្ត្រាចារ្យបានពន្យល់ថា លោកស្រី អៀង ធីរិទ្ធ អាចមើល

ម៉ោងនៅលើនាឡិកាដៃរបស់គាត់បានត្រឹមត្រូវ។ នេះមិនមែនជាការបង្ហាញអំពីការដឹងនូវពេលវេលាឡើយ។ ការដឹងពេលវេលា ត្រូវសាកសួរដោយសួរសំណួរជាក់លាក់ ដូចជា ការសួរអំពីថ្ងៃ កាលបរិច្ឆេទ ខែ រដូវ និងឆ្នាំ ហើយដោយគ្មានជំនួយពីខាងក្រៅ។ នៅក្នុងរបាយការណ៍ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១១ សាស្ត្រាចារ្យ ចក ធីតា បានបញ្ជាក់ថា លោកស្រី អៀង ធីរិទ្ធ "ពុំមានការចងចាំភ្លាមៗ [sic]" ទេ ហើយថា គាត់ជឿថា គេនឹងមកយកគាត់ចេញពីមន្ទីរឃុំឃាំងទៅក្រៅវេលាម៉ោង ២:០០ រសៀលនៅថ្ងៃនោះ។ ក្នុងការបញ្ជាក់ឱ្យបានច្បាស់ សាស្ត្រាចារ្យ ចក ធីតា បានពន្យល់ថា លោកស្រី អៀង ធីរិទ្ធ បានប្រាប់លោកស្រីសាស្ត្រាចារ្យថា គាត់បានទិញសំលៀកបំពាក់ពីខាងក្រៅដើម្បីត្រៀមចេញពីមន្ទីរឃុំឃាំង។ សាស្ត្រាចារ្យ ចក ធីតា ក៏បានបញ្ជាក់ផងដែរថា លោកស្រីពុំបានប្រមូលប្រវត្តិព័ត៌មាន នៅក្នុងការវាយតម្លៃរបស់លោកស្រីឡើយ។ ទោះបីជាយ៉ាងនេះក៏ដោយ លោកស្រីសាស្ត្រាចារ្យបានសន្និដ្ឋាននៅក្នុងរបាយការណ៍របស់លោកស្រីថា លោកស្រី អៀង ធីរិទ្ធ ពុំមានសញ្ញាណនៃជំងឺវិកលចរិតទេ។ នៅក្នុងការសម្ភាសន៍របស់លោកស្រីជាមួយយើង សាស្ត្រាចារ្យ ចក ធីតា បានបញ្ជាក់ថា តាមទស្សនៈរបស់លោកស្រី សមត្ថភាពផ្នែកបញ្ញាស្មារតីរបស់លោកស្រី អៀង ធីរិទ្ធ ក្នុងរយៈពេលប៉ុន្មានខែកន្លងទៅនេះ ពុំមានភាពល្អប្រសើរឡើងឡើយ ហើយថា ការចងចាំរបស់គាត់ "នៅដដែល"។ យើងបានសួរសាស្ត្រាចារ្យ ចក ធីតា អំពីថាតើគាត់បានធ្វើតេស្តត្រួតពិនិត្យស្ថានភាពផ្លូវចិត្តរយៈពេលខ្លីដែរ ឬទេ ហើយគាត់បាននិយាយថា គាត់បានធ្វើនៅពេលថ្មីៗនេះ ប៉ុន្តែមិនអាចចាំពិន្ទុឡើយ។ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ យើងទទួលបានរបាយការណ៍ថតចម្លងពីរបន្ថែមទៀត ដែលផ្ញើតាមម៉ាស៊ីនទូរសារពីសាស្ត្រាចារ្យ ចក ធីតា ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២ និងថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១២។ យើងដឹងថា របាយការណ៍ទីមួយក្នុងចំណោម របាយការណ៍ទាំងនេះ រួមមានតេស្តត្រួតពិនិត្យស្ថានភាពផ្លូវចិត្តរយៈពេលខ្លី ដោយមានពិន្ទុ ២៤ លើ ៣០។ យើងកត់សម្គាល់ថា ពិន្ទុនេះមិនស៊ីសង្វាក់គ្នាជាមួយនឹងពិន្ទុនៃការត្រួតពិនិត្យស្ថានភាព ផ្លូវចិត្តរយៈពេលខ្លីដែលបានធ្វើកំណត់ហេតុចំនួន ៨ ផ្សេងទៀតនៅឆ្នាំ ២០១១ និងឆ្នាំ ២០១២ ឡើយ ដែលការត្រួតពិនិត្យទាំងនោះ ពុំមានការត្រួតពិនិត្យណាមួយបានពិន្ទុលើសពី ១៨ ឡើយ (សូមមើលខាងក្រោម) ហើយការត្រួតពិនិត្យចំនួនបីក្នុងចំណោមការត្រួតពិនិត្យទាំងនោះ ត្រូវបានធ្វើឡើងដោយបុគ្គលិកថែទាំសុខភាព ហើយពុំមែនជាផ្នែកនៃការវាយតម្លៃអំពីសម្បទា របស់គាត់ក្នុងការ

ឆ្លើយតបទៅនឹងបទចោទ និងសម្បទាក្នុងការចូលរួមនៅក្នុងការជំនុំជម្រះក្តី។ ការពិនិត្យឡើងវិញទៅលើការធ្វើតេស្តត្រួតពិនិត្យស្ថានភាពផ្លូវចិត្តរយៈពេលខ្លីរបស់សាស្ត្រាចារ្យ ចក ធីតា នៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២ បង្ហាញថា គាត់ហាក់ដូចជាពុំបានអនុវត្តតេស្តឱ្យបានត្រឹមត្រូវឡើយ ហើយសំណួរមួយចំនួនត្រូវបានដាក់ជំនួស ដោយសំណួរដែលពុំសូវតម្រូវឱ្យមានការពិចារណាច្រើនឡើយ។ នៅពេលដែលយើងផ្តល់ពិន្ទុឡើងវិញទៅលើតេស្ត ដោយប្រើប្រាស់សំណៅតេស្តដែលមានលក្ខណៈស្តង់ដារនោះ លោកស្រី អៀង ធីរិទ្ធ ទទួលបានពិន្ទុចំនួន ១៥។

41. យើងដឹងថា ការសាកល្បងប្រើឱសថ Acetylcholinesterase និង Rivastigmine បានចាប់ផ្តើមនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (ដោយចាប់ផ្តើមប្រើថ្នាំបិតកម្រិត ៤,៦ មីលីក្រាមប្រចាំថ្ងៃ ដែលប្រហែលជាមួយខែក្រោយមក ត្រូវបានបង្កើនទៅប្រើថ្នាំបិតកម្រិត ៩,៥ មីលីក្រាមប្រចាំថ្ងៃ ដូចការប្រើប្រាស់ទូទៅ)។ បន្ថែមទៅនឹងការប្រើឱសថនេះ ក៏មានការអនុវត្តកម្មវិធីជំរុញផ្នែកបញ្ញាស្មារតី ចាប់ពីដើមខែ ឧសភា ឆ្នាំ ២០១២។ យើងធ្លាប់បានពន្យល់ពីមុនថា ការសាកល្បងប្រើវិធីព្យាបាលទាំងនេះរយៈពេល ៣ ខែ នឹងគ្រប់គ្រាន់ក្នុងការវាយតម្លៃថាតើការព្យាបាលទាំងនេះបានធ្វើឱ្យសមត្ថភាពផ្នែកបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ មានលក្ខណៈល្អប្រសើរឡើងរហូតដល់កម្រិតមួយ ដែលអាចឱ្យគាត់មានសម្បទាគ្រប់គ្រាន់ ក្នុងការឆ្លើយតបទៅនឹងបទចោទ និងក្នុងការចូលរួមនៅក្នុងការជំនុំជម្រះក្តីដែរ ឬយ៉ាងណា។ [redacted] បានពន្យល់ថា លោកស្រី អៀង ធីរិទ្ធ បានត្អូញត្អែរយ៉ាងខ្លាំងចំពោះថ្នាំ Rivastignine (ដោយប្រើបិតនៅលើស្បែក) ហើយថា ពុំមានការរាយការណ៍ណាមួយអំពីផលប៉ះពាល់ដោយសារការប្រើប្រាស់ឱសថនេះឡើយ។

42. លោក SREEDHARAN បានពន្យល់ថា ពុំមានការប្រែប្រួលគួរឱ្យកត់សម្គាល់ណាមួយនៃសមត្ថភាពផ្នែកបញ្ញាស្មារតី ឬការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ ឡើយ ចាប់តាំងពីចាប់ផ្តើមកម្មវិធីព្យាបាលផ្នែកបញ្ញាស្មារតីមក ប៉ុន្តែក៏ពុំឃើញមានការធ្លាក់អ្វីចុះគួរឱ្យកត់សម្គាល់ដែរ។ ដើម្បីត្រួតពិនិត្យទៅលើការវិវឌ្ឍន៍ លោក SREEDHARAN បានបញ្ជាក់ថា គាត់បានធ្វើការត្រួតពិនិត្យស្ថានភាពផ្លូវចិត្តរយៈពេលខ្លី ដែលជាការធ្វើតេស្តត្រួតពិនិត្យ ការចុះខ្សោយផ្នែកបញ្ញាស្មារតីដែលមានលក្ខណៈស្តង់ដារ ហើយនៅក្រោមការត្រួតពិនិត្យរបស់គាត់ បុគ្គលិកសុខាភិបាលពីរនាក់ដែលទទួលបានការបណ្តុះបណ្តាល បានអនុវត្តការធ្វើតេស្តនេះច្រើនដង

ទៀត។ លោកស្រី អៀង ធីរិទ្ធ បានពិន្ទុ ១២ (លើ ៣០) នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២[5] ហើយបន្ទាប់មកបានពិន្ទុ ១១ នៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១២[6] បានពិន្ទុ ១២ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២[7] ហើយបន្ទាប់មកបានពិន្ទុ ១៤ នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២[8]។ យើងកត់សម្គាល់ការពិនិត្យមុនៗដែលធ្វើឡើងដោយអ្នកជំនាញ ដែលនៅពេលនោះ គាត់បានពិន្ទុ ១៥ នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ និងបានពិន្ទុ ១៨ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១[9]។ យើងក៏កត់សម្គាល់ផងដែរថា ពិន្ទុទាំងនេះអាចខុសគ្នាពីរ ឬបីពិន្ទុក្នុងរយៈពេលមួយថ្ងៃ ដែលឆ្លុះបញ្ចាំងនូវការប្រែប្រួលជាធម្មតាក្នុងការចាប់អារម្មណ៍ និងការផ្តល់អារម្មណ៍ និងផលប៉ះពាល់ក្រោយៗមកទៀតនៃការធ្វើតេស្តនេះ ដែលគេគិតថា នឹងកើតមានទៅលើមនុស្សក្នុងវ័យចាស់។ យើងក៏បានកត់សម្គាល់ទៅលើការពិនិត្យពីលើកមុនដែលធ្វើឡើងដោយ សាស្ត្រាចារ្យ Campbell និងវេជ្ជបណ្ឌិត លីនណា នៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ដែលនៅពេលនោះ គាត់បានពិន្ទុ ១២[10]។ ទាក់ទិនទៅនឹងផ្នែកផ្សេងៗទៀតនៃស្ថានភាពផ្លូវចិត្ត របស់គាត់ លោក SREEDHARAN យល់ឃើញថា ទំនាក់ទំនងរបស់គាត់ជាមួយនឹងអ្នក ជំនាញព្យាបាលរោគដោយចលនា មានលក្ខណៈល្អប្រសើរនៅក្នុងអំឡុងពេលនេះ ប៉ុន្តែ អារម្មណ៍របស់គាត់នៅតែប្រែប្រួល ហើយជារឿយៗគាត់ហាក់ដូចជាគិតថា គាត់កំពុងតែរស់ នៅក្នុងសម័យមុន កាលពីគាត់ជាសិស្ស ឬជាគ្រូបង្រៀន។ លោក SREEDHARAN បាន បញ្ជាក់ថា គាត់ “ពុំមានមន្ទិល” ឡើយថា លោកស្រី អៀង ធីរិទ្ធ មាន“ការចុះខ្សោយផ្នែក បញ្ហាស្មារតីពីកម្រិតមធ្យមដល់កម្រិតធ្ងន់ធ្ងរ” ហើយគាត់គិតថា លោកស្រីនឹងមិនមានប្រសើរឡើងតាមរយៈការព្យាបាលដោយចលនា និងការជំរុញផ្នែកបញ្ហាស្មារតីបន្ថែមណាមួយទៀតឡើយ។

43. លោក ម៉ៅ សុភារម្យ បានលើកឡើងថា គាត់ជឿថា ការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ ពុំមានការប្រែប្រួលឡើយក្នុងអំឡុងរយៈពេលប៉ុន្មានខែកន្លងទៅនេះ។ បើទោះបីជាយ៉ាងណា គាត់បានកត់សម្គាល់ឃើញមានការប្រែប្រួលមួយក្នុងអំឡុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ

---

[5] E138/1/7/12
[6] E138/1/8/1.2
[7] E138/1/8/1.3
[8] E138/1/8/1
[9] E111/8, កថាខណ្ឌ២១។ ត្រង់នេះយើងនិយាយថាសាស្ត្រាចារ្យ Campbell បានឲ្យពិន្ទុ១៤ ក្នុងខែឧសភា ឆ្នាំ ២០១១។
[10] E138/1/7/4, ទំព័រ៤។

នោះ ដែលថាបច្ចុប្បន្នគាត់ "បានជេរ និងស្តីបន្ទោស" ទៅលើស្ត្រីពីររូបដែលជាបុគ្គលិកយាមមន្ទីរឃុំឃាំងញឹកញាប់ជាងពេលកន្លងមក។ ស្ត្រីទាំង ២ រូបនោះ ដែលយើងបានសម្ភាសន៍បានបញ្ជាក់អះអាងអំពីបញ្ហានេះ។ បន្ថែមពីលើនេះទៀត ពួកគាត់បានបញ្ជាក់ប្រាប់ថា ជាប្រក្រតីលោកស្រី អៀង ធីរិទ្ធ មិនអាចគ្រប់គ្រងការបត់ជើងតូចរបស់គាត់បាន ហើយបញ្ហានេះកាន់តែយ៉ាប់យឺនទៅក្នុងអំឡុងខែមុននេះ។ ពួកគាត់ក៏បានគូសបញ្ជាក់ថា លោកស្រី អៀង ធីរិទ្ធ ពុំដឹងថា គាត់គ្មានសមត្ថភាពគ្រប់គ្រងការបត់ជើងតូចរបស់គាត់ឡើយ ហើយនៅពេលមានការសាកសួរ គាត់បដិសេធអំពីបញ្ហានេះ។ ជាងនេះទៀត ស្ត្រីអ្នកយាមមន្ទីរឃុំឃាំងទាំងនេះបានបញ្ជាក់ប្រាប់ថា លោកស្រី អៀង ធីរិទ្ធ បាននិយាយប៉ុន្មានលើកក្នុងអំឡុងរយៈពេលប៉ុន្មានខែចុងក្រោយថា មានមនុស្សម្នាក់បង្ហាញខ្លួនក្នុងមុងរបស់គាត់។ ពួកគាត់បាននិយាយថា គាប់ជួនពេលខ្លះ លោកស្រី អៀង ធីរិទុធ រាយការណ៍ប្រាប់ថា នេះគឺជាមនុស្ស (ដែលគាត់ពុំស្គាល់ និងពុំដឹងថាឈ្មោះអ្វីទេ) ហើយនៅពេលខ្លះទៀត ថាជាកុមារ ឬលលាដ៍ក្បាល។ អ្នកយាមមន្ទីរឃុំឃាំងទាំងនោះបានពន្យល់ប្រាប់ថា លោកស្រី អៀង ធីរិទ្ធ ពុំជឿពួកគាត់ឡើយ នៅពេលពួកគាត់ពន្យល់ប្រាប់គាត់ថា ពុំមានអ្វីដូចដែលគាត់បាននិយាយឡើយ ហើយគាត់បានសុំយកមុងរបស់គាត់ចេញពីបន្ទប់ឃុំឃាំងដោយខ្លួនគាត់ផ្ទាល់ ប្រសិនបើបុគ្គលិកមន្ទីរឃុំឃាំងពុំយកមុងរបស់គាត់ចេញទេនោះ។ នៅពេលដែលយើងសួរបុគ្គលិកសន្តិសុខនៃមន្ទីរឃុំឃាំងថាតើបញ្ហានេះបានកើតឡើងញឹកញាប់ប៉ុណ្ណា ពួកគាត់បានបញ្ជាក់ថា "ញឹកញាប់គួរសម" ដែលពួកគាត់ចង់និយាយថា មានចំនួន "លើសពីដប់លើក"។ ពួកគាត់បានពន្យល់ថា លោកស្រី អៀង ធីរិទ្ធ ត្រូវការការរំឭកដដែលៗអំពីតម្រូវការក្នុងការលាងសម្អាតខ្លួនរបស់គាត់ ហើយគាត់ត្រូវការជំនួយក្នុងពេលងូតទឹក ប៉ុន្តែគាត់អាចស្លៀកសម្លៀកបំពាក់ដោយខ្លួនឯងដោយពុំត្រូវការជំនួយទេ។

44. [redacted] [redacted] យល់ថា ការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ ពុំមានការប្រែប្រួលឡើយ ចាប់តាំងពេលចាប់ផ្តើមអនុវត្តកម្មវិធីជំរុញផ្នែកបញ្ញាស្មារតីមក។ គាត់ក៏បានបញ្ជាក់អះអាងអំពីប្រវត្តិនៃការពុំមានសមត្ថភាពគ្រប់គ្រងការបត់ជើងតូចរបស់លោកស្រី អៀង ធីរិទ្ធ ដូចខាងលើផងដែរ ដែលគាត់និយាយថា បញ្ហានេះកាន់តែបង្ហាញឲ្យឃើញច្បាស់ក្នុងអំឡុងខែចុងក្រោយនេះ ហើយអនាម័យផ្ទាល់ខ្លួនរបស់គាត់បានធ្លាក់ចុះ។ នៅពេលគាត់បានលើកឡើង

ជាមួយលោកស្រី អៀង ធីរិទ្ធ អំពីបញ្ហាពួកសើម នៅពេលព្រឹកកាលពីប៉ុន្មានថ្ងៃមុន លោកស្រី អៀង ធីរិទ្ធ បាននិយាយថា មានមនុស្សចូលមកក្នុងបន្ទប់របស់គាត់ និងបានចាក់ទឹកលើគ្រែរបស់គាត់។ [redacted] ក៏បានពន្យល់ទៀតថា លោកស្រី អៀង ធីរិទ្ធ បានត្អូញត្អែរ "ញឹកញាប់ណាស់" ថា មានមនុស្សនៅក្នុងមុងរបស់គាត់ ហើយលោកស្រី អៀង ធីរិទ្ធ ក៏បាននិយាយថា នៅពេលខ្លះ មានមនុស្សកំពុងអង្គុយលើទូរទស្សន៍របស់គាត់ និងធ្លាប់បានសុំឱ្យ [redacted] ផ្លាស់មនុស្សនេះទៅកន្លែងផ្សេង ឬសំឡុតមនុស្សនេះឱ្យចេញឆ្ងាយ (ដោយមនុស្សដែលគាត់បាននិយាយ មានអត្តសញ្ញាណខុសៗគ្នា)។ អាការៈបែបនេះបានកើតមាន "យ៉ាងហោចណាស់ ម្តងក្នុងមួយសប្តាហ៍"។ បន្ថែមលើនេះទៀត [redacted] បាននិយាយ ថា លោកស្រី អៀង ធីរិទ្ធ ចំណាំគាត់ពុំបានត្រឹមត្រូវឡើយ ហើយពេលខ្លះបានគិតថា គាត់ជាឪពុក ពេលខ្លះទៀតជាប្តីទៅវិញ ប៉ុន្តែពុំដែលគិតថាគាត់ជាគិលានុបដ្ឋាយិកាឡើយ។ គាត់ក៏បានកត់សម្គាល់ឃើញថា នៅពេលខ្លះលោកស្រី អៀង ធីរិទ្ធ មានបញ្ហាការស្លៀកសម្លៀកបំពាក់ ហើយជួនកាលគាត់ពាក់អាវទ្រនាប់ពីរ ឬស្លៀកខោខ្លីលើសពីមួយ ប៉ុន្តែលោក មាន បាននិយាយថា គាត់ពុំបានដឹងថាតើនេះជាបញ្ហាថ្មីដែរ ឬយ៉ាងណាឡើយ។

45. លោក អៀង សារី បានពន្យល់ប្រាប់សាស្ត្រាចារ្យ Campbell ថា គាត់គិតថា ការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ កាន់តែមានភាពយ៉ាប់យឺនក្នុងអំឡុងឆ្នាំចុងក្រោយនេះ។ គាត់ក៏បានលើកឡើងថា បន្ទាប់ពីកូនៗបានមកលេងលោកស្រី អៀង ធីរិទ្ធ និងបានជួយងូតទឹកឱ្យគាត់នៅថ្ងៃដដែលនោះ លោកស្រីមិនចាំការមកសួរសុខទុក្ខរបស់កូនៗទាំងនោះឡើយ។

46. យើងបានសម្ភាសន៍លោកស្រី អៀង ធីរិទ្ធ ចំនួន ៣ លើកក្នុងអំឡុងរយៈពេល ២ ថ្ងៃ។ កិច្ចសម្ភាសន៍លើកទីមួយជាកិច្ចសម្ភាសន៍ខ្លី ហើយលោកស្រី អៀង ធីរិទ្ធ ពុំទទួលរាក់ទាក់យើងទេ ហើយបានប្រកែកពុំព្រមសហការក្នុងការវាយតម្លៃរបស់អ្នកជំនាញទាំងអស់នេះទេ ហើយម្តងគាត់និយាយថា គាត់ចង់ជួបអ្នកនេះ ម្តងគាត់និយាយថា គាត់ចង់ជួបអ្នកនោះ។ ប៉ុន្មាននាទីក្រោយមក យើងបានបញ្ឈប់កិច្ចសម្ភាសន៍នេះ។ នៅពេលដែលលោក អៀង សារី បានឃើញអាការៈបែបនេះ គាត់បានចូលទៅបន្ទប់របស់លោកស្រី អៀង ធីរិទ្ធ ដើម្បីជំរុញលោកស្រី អៀង ធីរិទ្ធ ឱ្យអនុញ្ញាតឱ្យយើងបន្តកិច្ចសម្ភាសន៍ ប៉ុន្តែគាត់បានប្រាប់យើងខ្ញុំថា លោកស្រី អៀង ធីរិទ្ធ ពុំស្គាល់គាត់ថាជាប្តីឡើយ បែរជាហៅគាត់ថាជាឪពុកទៅវិញ។ ប៉ុន្តែ

នៅវេលារសៀលក្រោយនោះបន្តិច គាត់បានយល់ព្រមឲ្យយើងធ្វើសម្ភាសន៍ និងមានការសហការរីករាយ ក្នុងអំឡុងពេលសម្ភាសន៍ដែលយើងបានធ្វើនៅក្នុងបន្ទប់របស់គាត់។ នៅថ្ងៃបន្ទាប់ យើងបានសម្ភាសន៍គាត់នៅក្នុងបន្ទប់ប្រជុំមួយនៅក្នុងមន្ទីរឃុំឃាំង ដែលនៅពេលនោះគាត់មានអារម្មណ៍ល្អ ចេះសហការ និងហាក់ដូចជារីករាយក្នុងការផ្ដល់កិច្ចសម្ភាសន៍ម្ដងទៀត។

47. លោកស្រី អៀង ធីរិទ្ធ ភាគច្រើនមានលក្ខណៈធម្មតាក្នុងអំឡុងពេលសម្ភាសន៍នោះ ទោះបីជាលោកស្រីមានការឈឺចាប់ នៅពេលដែលលោកស្រីប្ដូរពីអង្គុយទៅជាឈរវិញក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ គាត់បានដើរចេញ ឬចូលបន្ទប់របស់គាត់ ដោយមិនត្អូញត្អែរអ្វីឡើយ ប៉ុន្តែលោកស្រីត្រូវការជំនួយពីបុគ្គលិកសន្តិសុខនៅពេលនោះ។ ក្នុងអំឡុងពេលសម្ភាសន៍ សំដីរបស់លោកស្រី មានចង្វាក់ និងមានសំឡេងធម្មតា។ គាត់បាននិយាយជាភាសាអង់គ្លេសម្ដងម្កាល ហើយនិយាយបានយ៉ាងត្រឹមត្រូវ។ នៅពេលមួយនោះ លោកស្រីបានច្រៀងចម្រៀងខ្លីមួយបទជាភាសាបារាំងអំពីប្រទេសកម្ពុជា។ ទោះបីជាយ៉ាងក៏ដោយ ជារឿយៗគាត់ឆ្លើយមិនចំទៅនឹងសំណួរដែលយើងបានសួរគាត់ឡើយ ហើយលោកស្រីនិយាយអំពីពេលដែលគាត់រៀននៅសាលា ជីវិតយុវវ័យ ឬអំពីគ្រួសាររបស់គាត់ នៅពេលដែលគាត់ឆ្លើយទៅនឹងសំណួរដែលទាក់ទិននឹងបញ្ហាផ្សេងៗទៅវិញ។ មិនមានការសន្ទនាកើតឡើងរបៀបឯកឯងនោះទេ។ ម្ដងម្កាល លោកស្រីមិនបាននិយាយដោយបានបញ្ចប់ឃ្លានីមួយៗត្រឹមត្រូវទេ ប៉ុន្តែហាក់ដូចជាថា លោកស្រីមិនបានដឹងខ្លួនឯងអំពីបញ្ហានេះទេ។ យ៉ាងណាក៏ដោយ ឃ្លាប្រយោគ និងវេយ្យាករណ៍ដែលលោកស្រីប្រើ ហាក់ដូចជាមានភាពធម្មតា។ អារម្មណ៍របស់លោកស្រីមិនហ្នឹងនរទេ ហើយលោកស្រីមានភាពប្រទូស្តរ៉ាយ និងខឹងសម្បារនៅក្នុងអំឡុងពេលសម្ភាសន៍លើកទីមួយ ប៉ុន្តែលោកស្រីបានឆ្លើយតបយ៉ាងសកម្ម និងញញឹមសមរម្យនៅពេលសម្ភាសន៍ក្រោយៗទៀត។ គាត់មិនបានរៀបរាប់អំពីការយល់ដឹងណាមួយដែលមានលក្ខណៈចម្លែកនោះទេ ក្នុងអំឡុងពេលកិច្ចសម្ភាសន៍នោះ។ លោកស្រីអាចរក្សាការផ្ដោតអារម្មណ៍របស់គាត់ និងមិនបានបង្ហាញនូវភាពនឿយហត់ឡើយ។

48. យើងបានព្យាយាមធ្វើការត្រួតពិនិត្យស្ថានភាពផ្លូវចិត្តរយៈពេលខ្លី ក្នុងពេលពីរថ្ងៃបន្តបន្ទាប់គ្នា។ នៅថ្ងៃទីមួយ គាត់មិនដឹងអំពីពេលវេលា ឬទីកន្លែង (ក្រៅតែពីបានដឹងអំពីប្រទេសនោះ)ទេ។ គាត់មិនអាចស្គាល់ ឬចងចាំវត្ថុចំនួនបី និងមិនអាចរាប់លេខថយក្រោយដោយធ្វើការដកលេខ

ម្តងចំនួន ៧ ១ទេ។ គាត់អាចប្រាប់ឈ្មោះវត្ថុពីរយ៉ាង ថាតាមឃ្លាខ្លីៗ និងអាចធ្វើតាមដំណាក់កាលនៃការណែនាំដែលមាន ៣ ជំហាន។ លទ្ធផលនេះមានន័យថា គាត់ទទួលបានពិន្ទុ ៧ នៃពិន្ទុទាំងអស់ប្រហែលជា ៣០ នោះ។ ទោះបីជាអារម្មណ៍របស់គាត់ប្រសើរឡើងច្រើននៅថ្ងៃទីពីរ ក៏គាត់បានវង្វេងអំពីពេលវេលា ប៉ុន្តែគាត់អាចស្គាល់ទីកន្លែង ដោយគាត់បានដឹងថា គាត់ស្ថិតនៅក្រុងភ្នំពេញ ប្រទេសកម្ពុជា ហើយដឹងថា គាត់កំពុងស្ថិតនៅជាន់ផ្ទាល់ដី។ ទោះបីជាយ៉ាងណាក៏ដោយ លោកស្រីមិនបានសហការនឹងកិច្ចការវាយតម្លៃដែលមានកិច្ចការចំនួនបីចុងក្រោយទេ ដោយគាត់បានលើកឡើងថា គាត់មិនយល់ថា គាត់ចាំបាច់ត្រូវធ្វើកិច្ចការទាំងនេះនោះទេ។ ប៉ុន្តែបើសន្មតថាគាត់អាចធ្វើតាមការណែនាំដែលមាន ៣ ជំហាននេះ គាត់អាចទទួលបានពិន្ទុ ៩។ ប្រសិនបើយើងសន្មតថា គាត់អាចធ្វើកិច្ចការចំនួនបីចុងក្រោយនេះដែលគាត់ទំនងជាមិនអាចធ្វើទេនោះ ពិន្ទុអតិបរមារបស់គាត់នឹងទទួលបាន ១២ ពិន្ទុ។ យើងយល់ឃើញថា ពិន្ទុទាបដែលជាលទ្ធផលនៃការត្រួតពិនិត្យស្ថានភាពផ្លូវចិត្តរយៈពេលខ្លីរបស់គាត់ មិនមែនជាការបន្លំធ្វើពុតនោះទេ ពីព្រោះគាត់ហាក់ដូចជាភ័ន្តច្រឡំសំណួរយ៉ាងច្បាស់។ គោលការណ៍ណែនាំកំណត់ថា ពិន្ទុពី ១០ ដល់ ២០ បង្ហាញអំពីការចុះខ្សោយផ្នែកបញ្ញាស្មារតីកម្រិតមធ្យម និងពិន្ទុក្រោម ១០ បង្ហាញអំពីការចុះខ្សោយកម្រិតធ្ងន់ធ្ងរ។

49. ការចងចាំរយៈពេលខ្លីរបស់លោកស្រី អៀង ធីរិទ្ធ មានភាពអន់ខ្សោយ។ ផ្អែកតាមការធ្វើតេស្ត គាត់មិនចងចាំវត្ថុចំនួនបីបន្ទាប់ពីពីរបីនាទីក្រោយមក។ នៅថ្ងៃទីពីរ គាត់មិនចាំសមាជិកក្រុមវាយតម្លៃឡើយ។ គាត់មិនអាចនិយាយអំពីរឿងអ្វីដែលគាត់បានអាននៅក្នុងកាសែតនោះទេ។ ក្នុងអំឡុងពេលសម្ភាសន៍ គាត់ភ្លេចនូវអ្វីដែលគាត់បាននិយាយពីរបីនាទីមុន ហើយទោះបីជានៅពេលគេរំឭកគាត់ពីអ្វីគាត់បាននិយាយក៏ដោយ ក៏គាត់នៅតែប្រកាន់ថា គាត់មិនបាននិយាយដូច្នេះ នោះទេ។

50. ការចងចាំរយៈពេលវែងរបស់លោកស្រី អៀង ធីរិទ្ធ មានភាពអន់ខ្សោយយ៉ាងខ្លាំង។ លោកស្រីអាចប្រាប់ឈ្មោះឪពុកម្តាយរបស់គាត់ ប៉ុន្តែគាត់បានប្រាប់ថា ម្តាយគាត់នៅរស់នៅឡើយ។ លោកស្រីបានបដិសេធថា គាត់មានកូន និងបាននិយាយម្តងហើយម្តងទៀតថា គាត់មកកន្លែងសព្វថ្ងៃនេះ តាំងពីលោកស្រីនៅក្មេងម្ល៉េះ។ គាត់មិនអាចចាំឈ្មោះប្តីគាត់ទេកាលពីថ្ងៃទីមួយ ប៉ុន្តែលោកស្រីអាចចាំឈ្មោះប្តីរបស់គាត់នៅថ្ងៃទីពីរ។ លោកស្រីមិនអាចចាំ

អសយដ្ឋានចុងក្រោយគាត់ ឬព្រះនាមរបស់ព្រះមហាក្សត្រនោះទេ។ គាត់បានប្រាប់ឈ្មោះអនុវិទ្យាល័យរបស់គាត់ នៅពេលសម្ភាសន៍លើកទីពីរ។ ការចងចាំព័ត៌មានទាក់ទងនឹងការអប់រំថ្នាក់ឧត្តមសិក្សារបស់គាត់ មានភាពខុសៗគ្នា។ នៅថ្ងៃទីមួយ គាត់និយាយថា គាត់បានសិក្សានៅបរទេស ប៉ុន្តែគាត់មិនចាំទីកន្លែងដែលគាត់បានទៅសិក្សានោះទេ។ នៅថ្ងៃទីពីរ គាត់និយាយថា គាត់បានសិក្សានៅសាកលវិទ្យាល័យមួយនៅក្នុងទីក្រុងភ្នំពេញ (ដែលយើងដឹងថាជាព័ត៌មានមិនត្រឹមត្រូវ) និងបានសិក្សាភាសាបារាំង និងភាសាអង់គ្លេស។ លោកស្រីបានផ្តល់ចម្លើយមិនស៊ីសង្វាក់គ្នា ទាក់ទិននឹងថាតើគាត់បានរៀបអាពាហ៍ពិពាហ៍ ហើយនៅថ្ងៃទីពីរ លោកស្រីបានលើកឡើងថា គាត់បានធ្វើការងារនៅក្នុងក្រសួងមួយរបស់រដ្ឋាភិបាល ផ្នែកសង្គមកិច្ច។ ក្នុងអំឡុងពេលនៃការធ្វើបទសម្ភាសន៍ដដែលនោះ គាត់បានផ្តល់ចម្លើយមិនស៊ីសង្វាក់គ្នាទាក់ទិននឹងថាតើគាត់គឺជាផ្នែកមួយរបស់ខ្មែរក្រហមដែរឬទេនោះ។

51. យើងយោងលើរបាយការណ៍របស់យើងកាលពីលើកមុន ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១១ អំពីលក្ខខណ្ឌៈវិនិច្ឆ័យសម្រាប់ប្រើប្រាស់ ដើម្បីវាយតម្លៃអំពីសម្បទាក្នុងការឆ្លើយតបទៅនឹងបទចោទ និងសម្បទាក្នុងការចូលរួមនៅក្នុងការជំនុំជម្រះក្តី[11]។

52. លោកស្រី អៀង ធីរិទ្ធ បានបដិសេធម្តងហើយម្តងទៀតថា គាត់មិនត្រូវបានចោទប្រកាន់អំពីបទណាមួយនោះទេ។ ប៉ុន្តែ នៅពេលលើកឡើងថា លោកស្រីត្រូវបានចោទប្រកាន់ពីបទមនុស្សឃាត គាត់បាននិយាយថា “ខ្ញុំមិនអាចសម្លាប់អ្នកណានោះទេ។ ស្ត្រីកម្ពុជា មានភាពទន់ភ្លន់។ គ្រួសាររបស់ខ្ញុំគឺជាគ្រួសារល្អ”។ ទាក់ទងនឹងបទទារុណកម្ម គាត់បាននិយាយថា “ខ្ញុំមិនដែលមានបទពិសោធន៍ធ្វើទារុណកម្មនោះទេ។ ខ្ញុំមិនដឹងអំពីវិធីធ្វើទារុណកម្មទេ”។ ទាក់ទិននឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ លោកស្រីបានពន្យល់ថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មានន័យថា “ជាការសម្លាប់ពូជសាសន៍ដទៃ” ប៉ុន្តែលោកស្រីបាននិយាយថា “គ្មានជនណាមួយហ៊ានប្រព្រឹត្តអំពើបែបនោះទេ”។ ទាក់ទិននឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា លោកស្រីបាននិយាយថា “នៅក្នុងក្រុមរបស់យើង យើងមិនដែលធ្វើអ្វីអាក្រក់នោះទេ”។ ផ្អែកតាមការឆ្លើយទាំងអស់នេះ យើងអាចសន្និដ្ឋានថា គាត់យល់ដឹងជាគោលអំពីបទចោទ និងមាន

[11] ឯកសារ E111/8 កថាខណ្ឌ៣៩។

សមត្ថភាពដើម្បីឆ្លើយតបទៅនឹងបទចោទ។ ទោះបីជាយ៉ាងណាក៏ដោយ យើងកត់សម្គាល់ឃើញថា យើងពិបាកស្វែងរកអត្ថន័យលម្អិតអំពីបទចោទទាំងនេះ ដោយសារតែគាត់ចាត់ទុកថា បទចោទទាំងនេះមិនជាប់ពាក់ព័ន្ធនឹងគាត់ទេ។

53. លោកស្រី អៀង ធីរិទ្ធ បាននិយាយនៅក្នុងចំណុចមួយនោះថា "អ្នកគ្រប់រូបនៅទីនេះមានក្រុមមួយ" ហើយក្រុមនេះ មានមេធាវីម្នាក់។ ប៉ុន្តែ លោកស្រីបានប្តូរប្រធានបទ និងបាននិយាយអំពីវិទ្យាល័យរបស់គាត់ នៅពេលដែលយើងសួរគាត់អំពីតួនាទីរបស់មេធាវី។ គាត់មិនអាចប្រាប់ឈ្មោះមេធាវីរបស់គាត់ ឬមិនអាចប្រាប់អំពីតួនាទីរបស់មេធាវីនោះទេ។ ផ្អែកតាមព័ត៌មាននេះ យើងយល់ឃើញថា ទោះបីជាលោកស្រីអាចសហការជាមួយមេធាវីក៏ដោយ ក៏លោកស្រីមិនអាចជួយប្រកបដោយអត្ថន័យក្នុងការរៀបចំការការពារខ្លួនរបស់គាត់នោះទេ។ ជាគោល ករណីនេះកើតឡើងដោយសារតែការចុះខ្សោយខាងការចងចាំរបស់គាត់ ដែលធ្វើប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សមត្ថភាពដើម្បីអាចផ្តល់មតិយោបល់ ប្រកបដោយការយល់ដឹងទៅលើព័ត៌មានទាក់ទិននឹងការការពារខ្លួនរបស់លោកស្រី។

54. លោកស្រី អៀង ធីរិទ្ធ បានបដិសេធមិនព្រមឆ្លើយសំណួរទាក់ទងនឹងផលវិបាកនៃការផ្តន្ទាទោសណាមួយឡើយ។ អ្វីទាំងអស់ដែលគាត់បាននិយាយគឺថា 'មេដឹកនាំមកពីប្រវត្តិសាសនាល្អ' ដែលការនិយាយនេះ យើងបានសន្និដ្ឋានថា គឺជាវិធីមួយក្នុងការនិយាយថា គាត់ និងបុគ្គលផ្សេងទៀតដែលបច្ចុប្បន្នកំពុងត្រូវបានជំនុំជម្រះក្តី គឺគ្មានទោសឡើយ។

55. ដោយផ្អែកលើមូលដ្ឋាននៃការសម្ភាសរបស់យើង សមត្ថភាពរបស់លោកស្រី អៀង ធីរិទ្ធ ក្នុងការតាមដានដំណើរការនីតិវិធី ហាក់ដូចជាចុះខ្សោយយ៉ាងខ្លាំង។ ទោះបីជាគាត់បានពន្យល់ថា តួនាទីរបស់ចៅក្រមគឺថា 'ជាទូទៅ ពន្យល់យើង' យ៉ាងណាក៏ដោយ ក៏កម្រិតនៃការចុះខ្សោយខាងបញ្ញាស្មារតីរបស់គាត់នឹងនាំឲ្យគាត់មិនអាចបញ្ចេញយោបល់ទៅលើអ្វី ដែលបាននិយាយនៅក្នុងតុលាការ ដោយមេធាវី ឬសាក្សី និងមិនអាចបញ្ចេញយោបល់ប្រកបដោយការយល់ដឹងទៅលើបញ្ហានោះឡើយ។

56. លោកស្រី អៀង ធីរិទ្ធ ហាក់ដូចជាមានសមត្ថភាពអាចលើកឡើងអំពីការការពារផ្សេងៗតទល់នឹងការចោទប្រកាន់ដែលយើងបានបង្ហាញជូនគាត់ ដោយមានទាំងការអះអាងថា គាត់ទទួលបានការចិញ្ចឹមថែទាំនៅក្នុងគ្រួសារមួយដ៏ល្អ កាលនោះគាត់នៅក្មេង និងជាស្ត្រីខ្មែរម្នាក់ដែល 'សុភាព'។ ទោះបីយ៉ាងណាក៏ដោយ ក៏គាត់ហាក់ដូចជាមិនមានសមត្ថភាពអាចយល់ដឹងអំពីភាពលម្អិតនៃភស្តុតាងនោះឡើយ។ យើងយល់ឃើញថា ចំណុចខ្វះខាតចម្បងរបស់លោកស្រី គឺពាក់ព័ន្ធនឹងបញ្ហានៃការចងចាំរយៈពេលខ្លីរបស់គាត់ ដែលនឹងដាក់កំហិតយ៉ាងធ្ងន់ធ្ងរទៅលើសមត្ថភាពរបស់គាត់ក្នុងការថ្លឹងថ្លែងព័ត៌មានដើម្បីបញ្ចេញយោបល់លើព័ត៌មាននោះ។

57. ក្នុងការស្វែងរកការការពាររបស់ខ្លួន លោកស្រី អៀង ធីរិទ្ធ បានរៀបរាប់ផ្ទុយគ្នាពីការពាក់ព័ន្ធរបស់គាត់ជាមួយខ្មែរក្រហម។ ដំបូង គាត់បាននិយាយថា គាត់មិនស្ថិតនៅក្នុងចំណោមពួកខ្មែរក្រហមឡើយ ពីព្រោះគាត់នៅក្មេងពេកនៅពេលនោះ ហើយបន្ទាប់មក គាត់បាននិយាយថា 'ខ្ញុំស្អប់ខ្មែរក្រហមខ្លាំងណាស់ ពីព្រោះពួកគេធ្វើការឃោសនាខ្លាំងណាស់...។ ពួកគេបានធ្វើបាបប្រជាជនផ្សេងទៀត។ រឿងនេះមិនត្រូវ...។ សម្រាប់ប្រជាជនធម្មតា វាហាក់ដូចថាស្លាប់ទាំងរស់...។ កូនប្រុស និងកូនស្រីរបស់កសិករត្រូវបានគេធ្វើបាប ហើយខ្ញុំមិនចូលចិត្តនោះទេ...។ ពួកគេពិតជាធ្វើបាបប្រជាជន'។ ទោះបីជាយ៉ាងនេះក្តី ក្នុងរយៈពេលតែមួយនាទីគាត់មិនអាចរំឭករឿងនេះបានឡើយ ហើយបាននិយាយថា 'នៅពេលណាដែលខ្ញុំបាននិយាយថាយើងបានធ្វើបាបប្រជាជន...យើងបានខិតខំបង្ហាញឲ្យអស់សមត្ថភាពថា យើងធ្វើល្អសម្រាប់ប្រជាជកម្ពុជា...ចាស ខ្ញុំនៅក្នុងក្រុមនោះ ឪពុកម្តាយខ្ញុំនៅក្នុងក្រុមនោះ...។ ចុងក្រោយបំផុត ខ្ញុំនៅក្នុងក្រុមខ្មែរក្រហម ហើយយើងមិនបានធ្វើបាបប្រជាជនទេ'។ មួយនាទីក្រោយមក គាត់បាននិយាយថា គាត់មិនដែលចូលរួមជាមួយខ្មែរក្រហមឡើយ។ ភ្លាមៗបន្ទាប់ពីនេះមក គាត់បានពន្យល់ថា ប្តីរបស់គាត់បានបង្កើតបក្សជាតិនិយមខ្មែរមួយដែលមានឈ្មោះហៅថាខ្មែរក្រហមដែរ ហើយគាត់គឺជាសមាជិកម្នាក់ដែរ។

អនុសាសន៍

58. តាមទស្សនៈរបស់យើងខ្ញុំ ពុំមានភស្តុតាងនៃការបានធូរស្រាលណាមួយឡើយ បន្ទាប់ពីការប្រើប្រាស់ឱសថ Rivastigmine និងកម្មវិធីលើកម្ពស់បញ្ញាស្មារតី។ យើងខ្ញុំយល់ឃើញថា ពេលវេលាគ្រប់គ្រាន់ ដើម្បីឲ្យការព្យាបាលទាំងនេះទទួលបានប្រសិទ្ធភាព បានកន្លងផុតទៅហើយ ប្រសិនបើការព្យាបាលទាំងនេះនឹងមានប្រសិទ្ធភាព។ អាស្រ័យហេតុនេះ យើងខ្ញុំសូមណែនាំឲ្យបញ្ឈប់ការប្រើប្រាស់ឱសថ Rivastigmine និងបញ្ឈប់កម្មវិធីជំរុញបញ្ញាស្មារតីតទៅទៀត។

59. យើងខ្ញុំគិតថាពុំមានការព្យាបាលណាផ្សេងទៀត ដើម្បីធ្វើឲ្យសមត្ថភាពបញ្ញាស្មារតីរបស់លោកស្រី អៀង ធីរិទ្ធ ល្អប្រសើរឡើងឡើយ។ យើងខ្ញុំសូមណែនាំឲ្យបន្តការព្យាបាលលោកស្រី អៀង ធីរិទ្ធ តាមក្បួនវេជ្ជសាស្ត្រផ្សេងៗទៀតដដែល ហើយតាមដានការព្យាបាលទាំងនោះតាមការសមស្រប និងនៅពេលយល់ថាមានភាពសមស្របយោងតាមក្រុមវេជ្ជសាស្ត្ររបស់គាត់។ យើងខ្ញុំពុំមានអនុសាសន៍ពាក់ព័ន្ធនឹងវេជ្ជសាស្ត្រផ្សេងពីនេះឡើយ។

សន្និដ្ឋាន

60. តាមការធ្វើរោគវិនិច្ឆ័យ យើងខ្ញុំនៅតែយល់ឃើញថា លោកស្រី អៀង ធីរិទ្ធ ពិតជាមានជំងឺវង្វេងស្មារតី។ យើងខ្ញុំចាត់ទុកស្ថានភាពជំងឺរបស់គាត់ថាជាជំងឺវង្វេងស្មារតីក្នុងកម្រិតមធ្យមទៅធ្ងន់ធ្ងរ។ គោលការណ៍ណែនាំអំពីការធ្វើរោគវិនិច្ឆ័យនៃចំណាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ [International Classification of Disease] (ICD-10) បោះពុម្ពផ្សាយលើកទី ១០ ដែលជាគោលការណ៍ណែនាំអំពីការធ្វើរោគវិនិច្ឆ័យជាបទដ្ឋានរបស់អង្គការសុខភាពពិភពលោក ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាអន្តរជាតិ ចែងលក្ខណៈវិនិច្ឆ័យចំនួន ៤ នៃជំងឺវង្វេងស្មារតី។ លក្ខណៈវិនិច្ឆ័យចំនួន ២ ដំបូងត្រូវមានអត្ថិភាពសម្រាប់រយៈពេលចំនួន ៦ ខែយ៉ាងតិច។ ទីមួយ ការធ្លាក់ចុះការចងចាំ ដែលជាការធ្លាក់ចុះងាយកត់សម្គាល់ឃើញជាងគេបង្អស់ក្នុងការដឹងអំពីព័ត៌មានថ្មីៗ ហើយក្នុង "ករណីធ្ងន់ធ្ងរជាងនេះ" ការធ្លាក់ចុះការចងចាំ ក៏ធ្វើឲ្យគាត់ភ្លេចភ្លាំងព័ត៌មានដែលគាត់ទើបតែបានដឹងថ្មីៗផងដែរ។ គោលការណ៍ណែនាំ ICD-10

ចែងថា ការធ្លាក់ចុះការចងចាំនេះអាចត្រូវបានចាត់ទុកថាមានភាពធ្ងន់ធ្ងរ ប្រសិនបើ "កម្រិតនៃការបាត់បង់ការចងចាំ ត្រូវបានសម្គាល់ដោយអសមត្ថភាពទាំងស្រុងក្នុងចងចាំព័ត៌មានថ្មីៗ។ មានតែផ្នែកខ្លះៗនៃព័ត៌មានថ្មីដែលបានរៀនពីមុនប៉ុណ្ណោះ ដែលនៅសេសសល់។ អ្នកជំងឺពុំមានលទ្ធភាពស្គាល់ សូម្បីតែសាច់ញាតិជិតៗរបស់ខ្លួនក៏ដោយ"។ យើងខ្ញុំយល់ឃើញថា លោកស្រី អៀង ធីរិទ្ធ កំពុងតែស្ថិតនៅក្នុងកម្រិតនៃភាពធ្ងន់ធ្ងរបែបនេះ។ លក្ខណៈវិនិច្ឆ័យទីពីរ គឺការធ្លាក់ចុះនៃសមត្ថភាពបញ្ញាស្មារតីផ្សេងៗទៀត ដែលស្តែងឡើងតាមរយៈការវិនិច្ឆ័យ និងការគិត។ គោលការណ៍ណែនាំ ICD-10 ពន្យល់ថា ភស្តុតាងសម្រាប់បញ្ជាក់អំពីភាពធ្ងន់ធ្ងរកម្រិតនេះ គួរចេញពីអ្នកសាកសួរអ្នកជំងឺ (អាចមានអ្នកសាកសួរម្នាក់ ឬច្រើននាក់) និងតេស្តស្តង់ដារ។ គោលការណ៍ណែនាំទាំងនេះចែងថា ជំងឺនេះអាចត្រូវបានចាត់ទុកថាមានស្ថានភាពមធ្យម ប្រសិនបើ "អ្នកជំងឺពុំមានលទ្ធភាពបំពេញមុខងារ ដោយពុំមានជំនួយពីអ្នកដទៃនៅក្នុងការរស់នៅប្រចាំថ្ងៃ...។ សកម្មភាពនានាត្រូវបានកំហិតកាន់តែខ្លាំងឡើង និងពុំមានភាពនឹងនរ"។ យោងទៅតាមព័ត៌មានដែលអ្នករាយការណ៍បានផ្តល់អំពីភាពអសមត្ថភាពនាពេលបច្ចុប្បន្នរបស់លោកស្រី អៀង ធីរិទ្ធ ក្នុងការថែទាំអនាម័យផ្ទាល់ខ្លួន និងការបន្ទោរបង់របស់គាត់ យើងខ្ញុំយល់ឃើញថា បញ្ហាទាំងនេះអាចត្រូវបានចាត់ទុកជាបញ្ហាមានភាពធ្ងន់ធ្ងរជាមធ្យមដែរ។យោងតាមគោលការណ៍ណែនាំ ICD-10 លក្ខណវិនិច្ឆ័យទីបីនៃជំងឺវង្វេងស្មារតីគឺអវត្តមាននៃការភាន់ភាំងស្មារតី ហើយចាប់តាំងពីពេលឃុំខ្លួនគាត់មក ពុំមានការរាយការណ៍អំពីការភាន់ភាំងស្មារតីនេះឡើយ។ លក្ខខណ្ឌទីបួនគឺការធ្លាក់ចុះនៃសមត្ថភាពគ្រប់គ្រងអារម្មណ៍ ឬស្មារតី ឬបម្រែបម្រួលនៃឥរិយាបទសង្គម ដែលត្រូវបានបង្ហាញជាក់ស្តែងដោយភាពច្រងេងច្រងាង និងអរិភាពជាពាក្យសម្តី ទៅកាន់បុគ្គលិកមន្ទីរឃុំឃាំងជាស្ត្រី និងការប្រែប្រួលអារម្មណ៍ដែលបុគ្គលិកមួយចំនួនបានរាយការណ៍។ ហេតុដូច្នេះ ជាសង្ខេប យើងខ្ញុំគិតថា លោកស្រី អៀង ធីរិទ្ធ មានរោគសញ្ញានៃជំងឺវង្វេងស្មារតី ដែលអាចត្រូវបានចាត់ទុកជាជំងឺវង្វេងស្មារតីក្នុងកម្រិតពីមធ្យមទៅធ្ងន់ធ្ងរ។

61. បើទោះបីជាយ៉ាងណា យើងខ្ញុំគិតថាជំងឺវង្វេងស្មារតីរបស់គាត់ បានវិវឌ្ឍន៍កាន់តែធ្ងន់ធ្ងរចាប់តាំងពីឆ្នាំ ២០១១ ហើយក៏មានការធ្លាក់ចុះបន្តិចបន្តួចនៃសមត្ថភាពបញ្ញាស្មារតីរបស់គាត់ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ បើទោះបីជាមានការព្យាបាលថ្មីៗនេះក៏ដោយ។ ការធ្លាក់

ចុះនៃសមត្ថភាពបញ្ញាស្មារតីរបស់គាត់ត្រូវបានមើលឃើញជាក់ស្តែង តាមរយៈភាពច្រងេងច្រងាងពាក្យសម្តីរបស់គាត់ដែលបានកើនឡើង ទៅបុគ្គលិកមន្ត្រីឃុំឃាំងជាស្ត្រី ការពុំមានសមត្ថភាពគ្រប់គ្រងការបត់ជើងតូចនាពេលថ្មីៗរបស់គាត់ និងការឆ្លើយតបដដែលៗទៅនឹងអាការៈនេះ និងការពុំមានកំណើននៃពិន្ទុរបស់គាត់នៅក្នុងការធ្វើតេស្តវាយតម្លៃផ្លូវចិត្តខ្លីៗ (MMSE) នានាក្នុងអំឡុងរយៈពេលនេះ។ កាលពីឆ្នាំទៅមិញ គាត់បានទទួលពិន្ទុ ១៤, ១៥ និង ១៨ លើពិន្ទុ ៣០ ដែលអាចជាពិន្ទុពេញ នៅក្នុងការវាយតម្លៃចំនួន ៣ ដែលយើងខ្ញុំបានធ្វើ[12]។ បើទោះបីជាយ៉ាងណា កាលពីខែ ឧសភា និង ខែសីហា ឆ្នាំ ២០១២ ពិន្ទុរបស់គាត់បានស្ថិតនៅក្នុងចន្លោះ ១១-១៤ ហើយក្នុងអំឡុងពេលធ្វើការវាយតម្លៃចំនួន ២ ដងរបស់យើងក្នុងការវាយតម្លៃនេះ គាត់បានទទួលពិន្ទុច្រើនបំផុតចំនួន ១២ និងអាចទទួលបានពិន្ទុទាបជាងនេះ។ បើទោះបីជាមានការប្រុងប្រយ័ត្នក្នុងការទុកពិន្ទុនៃការធ្វើតេស្តវាយតម្លៃផ្លូវចិត្តខ្លីៗមួយដាច់ដោយឡែកៗពីគ្នា ដោយហេតុថា ពិន្ទុអាចទទួលបានខុសពីគ្នា ចំនួន ២-៣ ពិន្ទុជាធម្មតា ពីមួយថ្ងៃ ទៅមួយថ្ងៃក៏ដោយ យើងកត់សម្គាល់ឃើញមានទំនោរទៅរកពិន្ទុទាបពីពេលមួយទៅពេលមួយទៀត ដែលលទ្ធផលបែបនេះស៊ីសង្វាក់ជាមួយរោគសញ្ញានៃជំងឺដែលចេះតែវិវឌ្ឍន៍ទៅមុខរបស់គាត់ ពោលគឺជំងឺវង្វេងស្មារតី។ ជាងនេះទៀត មានរបាយការណ៍អំពីការមមើមមាយទាក់ទិននឹងមុងរបស់គាត់ ដែលជាសញ្ញាវិវឌ្ឍន៍មួយទៀត ដោយហេតុថាពុំមានសញ្ញាបញ្ជាក់អំពីការមមើមមាយនេះឡើយ នៅពេលដែលយើងបានសម្ភាសន៍គាត់កាលពីឆ្នាំមុន។

62. យើងខ្ញុំនៅតែយល់ឃើញថា លោកស្រី អៀង ធីរិទ្ធ នឹងមានការលំបាកខ្លាំងក្នុងលក្ខណវិនិច្ឆ័យខ្លះ ដូចដែលបានបញ្ជាក់ខាងលើ ពាក់ព័ន្ធទៅនឹងសម្បទាដើម្បីឆ្លើយទៅនឹងបទចោទ និងចូលរួមក្នុងការជំនុំជម្រះក្តី។ ពិសេស ចំណុចទាំងនេះពាក់ព័ន្ធជាក់ស្តែងបំផុតទៅនឹងបញ្ហាក្នុងការពិគ្រោះជាមួយមេធាវី ការតាមដានកិច្ចដំណើរការនីតិវិធី និងការយល់សេចក្តីលម្អិតនៃភស្តុតាង។ ភាពអសមត្ថភាពធ្ងន់ធ្ងររបស់គាត់ក្នុងការចងចាំរយៈពេលខ្លី មានន័យថាគាត់នឹងមានការលំបាកខ្លាំងក្នុងការមានលទ្ធភាពចងចាំព័ត៌មានពាក់ព័ន្ធនឹងភស្តុតាងជាលាយលក្ខណ៍អក្សរ ឬជាពាក្យសម្តី បានយូរគ្រប់គ្រាន់ ដើម្បីឲ្យគាត់អាចធ្វើសេចក្តីអត្ថាធិប្បាយ

[12] ឯកសារ E111/8, កថាខណ្ឌ ២១ និងឯកសារ E62/3/6 កថាខណ្ឌ ១៧ និង ២៥។

ដោយការយល់ដឹងច្បាស់លាស់លើភស្តុតាងទាំងនោះ។ នៅពេលបច្ចុប្បន្ន ការធ្លាក់ចុះការចងចាំទាំងនេះ អាចប៉ះពាល់ដល់សមត្ថភាពក្នុងការផ្តល់សក្ខីកម្ម និងមានភស្តុតាងខ្លះដែលថាគាត់បានភ្លេចអ្វីដែលគាត់បាននិយាយនៅក្នុងអំឡុងកិច្ចសន្ទនាតែមួយ។

63. យើងខ្ញុំយល់ឃើញថា ការផ្លាស់ប្តូរនីតិវិធីតុលាការ នឹងពុំជួយលោកស្រី អៀង ធីរិទ្ធ ក្នុងកម្រិតមួយដែលអាចឲ្យគាត់មានសមត្ថភាពបំពេញលក្ខណៈវិនិច្ឆ័យ ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ៦២ ឡើយ។

ត្រូវបានចុះហត្ថលេខា

កាលបរិច្ឆេទ	ឈ្មោះ	ទីកន្លែង	ហត្ថលេខា
ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២	វេជ្ជបណ្ឌិត Seena Fazel	ភ្នំពេញ	
ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២	សាស្ត្រាចារ្យ John Campbell	ភ្នំពេញ	
ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២	ជំនួយការ សាស្ត្រាចារ្យ ហួត លីនណា	ភ្នំពេញ	